00281282

**Declassified to Public**
**06 September 2012**

**អ៊ុក នារី**

**៦៨ ផ្លូវ Henri Barbusse**

**92000 NANTERRE France**

E2/89.6

**ជូនចំពោះ**

**លោកចៅក្រមប្រធានអង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**កម្មវត្ថុ ÷ បណ្តឹងប្រឆាំងនឹង កាំងហ្កេចអ៊ាវ ហៅ ឌុច និង អៀង សារី**

លោកចៅក្រមប្រធានជាទីគោរព

លោក លោកស្រី សហព្រះរាជអាជ្ញាជាទីគោរព

នាងខ្ញុំសូមដាក់ពាក្យបណ្តឹងនៅចំពោះមុខលោកប្រឆាំងនឹង

- លោក កាំងហ្កេចអ៊ាវ ហៅ ឌុច
- និង លោក អៀង សារី

បុគ្គលដែលទទួលខុសត្រូវចំពោះការស្លាប់របស់ឪពុកខ្ញុំឈ្មោះ អ៊ុក កេត ដែលត្រូវបានសម្លាប់ក្នុងឆ្នាំ ១៩៧៧ បន្ទាប់ពីមានការឃុំឃាំងនៅមន្ទីរទួលស្លែង ហៅថា ស ២១ ។

នាងខ្ញុំគឺជាកូនស្រីខ្មោចលោក អ៊ុក កេត និងអ្នកស្រី Martine LEFEUVRE ដែលត្រូវជាប្រពន្ធលោក អ៊ុក កេត ។ នាងខ្ញុំកើតនៅ ថ្ងៃទី ១៦ ខែ កក្កដា ១៩៧៥ នៅទីក្រុង ដាកា ប្រទេស សេណេហ្កាល់ ។

ឪពុករបស់ខ្ញុំ អ៊ុក កេត ជាអគ្គរាជទូតកម្ពុជា កើតនៅ ថ្ងៃទី ១ ខែ សីហា ១៩៤៦ នៅទីក្រុងភ្នំពេញ ។ គាត់បានបាត់ខ្លួន នៅខែ មិថុនា ១៩៧៧ នៅពេលដែលខ្ញុំមានអាយុទើបតែ ២ឆ្នាំ ។

ដោយរស់នៅបែកពីឪពុក នាងខ្ញុំបានចាកចេញទៅប្រទេសបារាំងជាមួយម្តាយ បងប្រុសនិងជីដូនម្តាយរបស់ខ្ញុំ ។ នាងខ្ញុំបានសិក្សានៅទីនោះ និងធ្វើការជាបុគ្គលិកអាកាសចរណ៍ខាងផ្នែក Division Asie/ Pacifique/ Chine ក្នុងក្រុមហ៊ុន អាកាសចរAir France។

ទាំងក្នុងកុមារភាព និងយុវវ័យភាពរបស់ខ្ញុំ រស់នៅដោយគ្មានភាពកក់ក្តៅសោះព្រោះតែការបាត់ខ្លួនរបស់ឪពុកខ្ញុំ ។

00281283



ភាពឯកកោរ ការរងទុក្ខ និងសេចក្ដីទុក្ខព្រួយ នៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ ។

ផ្ទុយទៅវិញ ការចង់ដឹងចង់ឃើញការពិតមិនបានបាត់រលត់នោះទេ ។

ហេតុនេះ ក្នុងអាយុ១៦ឆ្នាំ ខ្ញុំ ម្ដាយនិងបងប្រុសរបស់ខ្ញុំ បានត្រឡប់ទៅភ្នំពេញ បន្ទាប់មកទៅទួលស្លែង គឺនៅទីនោះហើយដែលនាងខ្ញុំបានឃើញសេចក្ដីវន្ទត់ដ៏ធំមហិមានៃសកម្មភាពរបស់ លោក កាំងហ្កេចអ៊ាវ ហៅ ឌុច ដូចជារណ្ដៅសាកសពរួមនៅបឹងជើងឯកដែលជាទីតាំងនៃអំពើហិង្សាគ្រប់ប្រភេទ ដីដែលមានស្នាមឈាមកកនៅឡើយ ឆ្អឹងនៅរាយពាសពេញជាមួយនឹងចំណងនៅឡើយ គឺជាភស្តុតាងរបស់មនុស្សល្ងង់ខ្លៅទាំងនោះ ។

នាងខ្ញុំចង់បាននូវចម្លើយពីអ្វីដែលឪពុករបស់ខ្ញុំបានទទួលរងនៅក្នុងមន្ទីរនោះ ពីលេខរៀងបន្ទប់ឃុំខ្លួនរបស់គាត់ និងចម្លើយសារភាពដែលទទួលបានបន្ទាប់ពីការធ្វើទារុណកម្មរយៈពេល៦ខែ ហើយនៅតែរកមិនឃើញនូវចម្លើយទាំងនោះសោះ ។

ម្យ៉ាងទៀត ការបាត់ខ្លួនឪពុករបស់ខ្ញុំបានបណ្ដាលអោយម្ដាយ បងប្រុស និងរូបខ្ញុំផ្ទាល់រងនូវផលលំបាកទាំងខាងសម្ភារៈក៏ដូចជាខាងផ្លូវចិត្ត ។

ដើម្បីធ្វើអោយខ្ញុំមានលក្ខណៈដូចដើមវិញ ខ្ញុំបានទៅប្រឹក្សាជាមួយគ្រូពេទ្យចិត្តសាស្ត្របន្ទាប់ពីការចេញផ្សាយភាពយន្ត ឯកសារ " មន្ទីរ ស២១ មានចំណងជើងថា ម៉ាស៊ីនពិឃាតខ្មែរក្រហម " ដែលបានរៀបរាប់នៅក្នុងអំឡុងពេលនៃ ដំណើរប្រព្រឹត្តទៅនៃលទ្ធិសម្លាប់រង្គាល ដែលកាំងហ្កេចអ៊ាវ ហៅ ឌុច និងអៀង សារី បានធ្វើជាឈ្នាន់នៃការសម្លាប់ ។

បន្ទាប់ពីភាពស្ងៀមស្ងាត់អស់រយៈពេលសាមសិបឆ្នាំមក ខ្ញុំឃើញច្បាស់ថា ទីបញ្ចប់ភាសាផ្សេងៗបង្ហាញអោយឃើញ ពីការបង្កើតអោយមានឡើងវិញនូវសច្ចភាពប្រវត្តិសាស្ត្រ ។

នាងខ្ញុំមិនចង់បិទភ្នែកទាំងគួរបំភ្លេចចោលនូវអ្វីដែលបានកើតមានឡើងយ៉ាងពិតប្រាកដនៅទួលស្លែងនោះទេ ។ នាងខ្ញុំចង់រកអោយឃើញជាថ្មីឡើងវិញនូវភាពស្រដៀងគ្នានៃតុល្យភាព ។ នាងខ្ញុំចង់បញ្ចប់ណាស់នូវទុក្ខសោកដែលមាន ហើយបន្តការរស់នៅជាថ្មីឡើងវិញ។

ដើម្បីធ្វើដូច្នោះ ខ្ញុំត្រូវការអោយមានយុត្តិធម៌ ។

កាំងហ្កេចអ៊ាវ ហៅ ឌុច និងអៀង សារី អ្នកដែលទទួលខុសត្រូវចំពោះការបាត់ខ្លួនឪពុករបស់ខ្ញុំ ត្រូវតែឆ្លើយចំពោះអំពើរបស់ខ្លួនបានធ្វើ នៅចំពោះមុខតុលាការថា៖

- គឺលោក អៀង សារី ហ្នឹងហើយដែលបានចុះហត្ថលេខាលើការវិលត្រឡប់មកកម្ពុជាវិញរបស់ឪពុកខ្ញុំ

E2/89.6

ទាំងដឹងពីគ្រប់បរិបទសង្គមនៅក្នុងប្រទេសនៅក្នុងអំឡុងពេលដែលមានការសម្លាប់ជាលក្ខណៈប្រព័ន្ធ និង ទូទៅលើប្រជាជនកម្ពុជា និងបញ្ញវន្តរបស់ខ្លួន ។

- គឺលោក កាំងហ្គេចអ៊ាវ ហៅ ឌុច ដែលបានចាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ។

ពួកគាត់បានបំបែកខ្ញុំពីឪពុករបស់ខ្ញុំ ពីកុមារភាពរបស់ខ្ញុំ និងនិយាយអោយចំទៅគឺការបំផ្លាញនូវជីវិតធម្មតារបស់ខ្ញុំ ដែលស្ថិតនៅក្នុងទំនាក់ទំនងដ៏ល្អឥតខ្ចោះនៃវប្បធម៌ពីររបស់ខ្ញុំ ។

នាងខ្ញុំដាក់ពាក្យបណ្តឹងនៅថ្ងៃនេះនៅចំពោះមុខលោក ប្រឆាំងនឹងបុគ្គលទាំងនោះ ពីការដែលបានចាប់ឪពុករបស់ខ្ញុំ អ៊ុក កេត នៅថ្ងៃទី ១៥ មិថុនា ១៩៧៧ នៅក្រសួងការបរទេសនៅភ្នំពេញ ដែលជាក្រសួងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ លោក អៀង សារី ។ ពីការដែលបានឃុំឃាំង ដាក់គុក ធ្វើទារុណកម្ម នៅមន្ទីរឃុំឃាំងទួលស្លែងដោយបំបិទ នូវគ្រប់ការទាក់ទងជាមួយគ្រួសារ ប្រពន្ធ និងកូនៗរបស់គាត់ និងគ្រប់មធ្យោបាយថែទាំសុខភាព ។ ពីការដែលត្រូវបានសម្លាប់នៅថ្ងៃទី ៩ ធ្នូ ១៩៧៧ ។

ដូចគ្នាដែរ នាងខ្ញុំដាក់ពាក្យបណ្តឹងប្រឆាំងនឹងបុគ្គលទាំងនោះ ដែលបានបិទបាំងរាល់ភស្តុតាងពីគ្រួសារ អ៊ុក កេត ធ្វើអោយគ្រួសារនាងខ្ញុំមិនអាចធ្វើបុណ្យកាន់ទុក្ខសម្រាប់គាត់ ព្រោះសាកសពរបស់គាត់ត្រូវបានគេបោះចោលនៅក្នុងរណ្តៅរួម ។

ចាប់ពីពេលនេះតទៅ នាងខ្ញុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធី ប្រឆាំងនឹងពួកគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ពាក់ព័ន្ធនឹងការជួសជុលសំណងជម្ងឺចិត្តនៃព្យសនកម្មផ្លូវចិត្ត ដែលនាងខ្ញុំទទួលរងពីការដែលបាត់បង់ឪពុក ចំពោះគ្រប់ការរងទុក្ខវេទនាដែលបានកើតឡើងទាំងនោះ នាងខ្ញុំស្នើសុំអោយរឹបអូសនូវចលនទ្រព្យ និងអចលនទ្រព្យទាំងអស់របស់លោក កាំងហ្គេចអ៊ាវ ហៅ ឌុច និងលោក អៀង សារី ។ សូមអោយមានការព្យាបាលដោយមិនគិតថ្លៃ នៅតាមមន្ទីរពេទ្យសំរាប់កុមារក្នុងគ្រួសាររបស់ខ្ញុំ ដែលរស់នៅប្រទេសកម្ពុជា ដែលពួកគាត់បានចំណាយជាច្រើនទៅ លើការបង់សេវាទាំងនេះ ព្រមជាមួយនឹងការរៀបចំរណ្តៅសពរួមជាថ្មី ដោយគាស់សាកសពជនរងគ្រោះនៃរបបខ្មែរក្រហម។

ម្យ៉ាងទៀត នាងខ្ញុំស្នើសុំដូចគ្នាដែរអោយមានការបោះពុម្ពផ្សាយដីកាតុលាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និង អន្តរជាតិ ។

ធ្វើនៅថ្ងៃទី ១៤ មករា ២០០៩

00281285

E2/89.6

នាងខ្ញុំភ្ជាប់មកជាមួយបណ្តឹងរបស់ខ្ញុំនូវឯកសារដូចខាងក្រោម៖

1. រូបថតរបស់ អ៊ុក កេត
2. សញ្ញាបត្រពី Ecole Européenne de Statistiques
3. លិខិតរបស់ អ៊ុក កេត (ដែលនិយាយពីស្ថានភាពសង្គមនយោបាយនៅក្នុងប្រទេសរបស់គាត់)
4. លិខិតរបស់ Petch Cheaing ឯកអគ្គរាជទូតនៃស្ថានទូតនៅទីក្រុងប៉េកាំង ដើម្បីត្រឡប់ចូលស្រុកវិញ
5. កាតប៉ូស្តាល់ចុងក្រោយទទួលនៅប្រទេសបារាំង (២)
6. បញ្ជីអ្នកទោសត្រូវសម្លាប់នៅទួលស្លែង ថ្ងៃទី ៩ ធ្នូ ១៩៧៧
7. លិខិតរបស់ប្រតិភូកាកបាទក្រហមថៃចុះថ្ងៃទី ១១ មិថុនា ១៩៩៣
8. សម្រង់សំបុត្ររៀបអាពាហ៍ពិពាហ៍ចុះថ្ងៃទី ១ តុលា ១៩៧១
9. សម្រង់សំបុត្រកំណើតរបស់ អ៊ុក នារី កើតថ្ងៃទី ១៦ កក្កដា ១៩៧៥
10. លិខិតឆ្លងដែនការទូតរបស់អ្នកស្រី Martine LEFEUVRE ភរិយាលោក អ៊ុក កេត ដែលជាលេខាទី៣ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសសេណេហ្គាល់
11. លិខិតទទួលនៅថ្ងៃទី ៣ ឧសភា ១៩៧៩ ដោយអ្នកស្រី Martine OUK
12. អ៊ីមែល ថ្ងៃទី ៦ ឧសភា ១៩៩៨ របស់ Mark Norris ជូនចំពោះ កញ្ញា អ៊ុក នារី
13. អ៊ីមែល ថ្ងៃទី ១៣ មករា ២០០៥ របស់លោក ឆាំង យុ ជូនចំពោះកញ្ញា អ៊ុក នារី
14. ការបកប្រែលិខិតរបស់លោក Craig ETCHESON
15. លិខិតចុះថ្ងៃទី ២០ មិនា ១៩៧៩
16. លិខិតបញ្ជាក់របស់វេជ្ជបណ្ឌិត DUPEYROUX ចុះថ្ងៃទី ១៤ មករា ២០០៩